**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល
(ខេមបូឌា) ភីអិលស៊ី

*រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែមិថុនា ឆ្នាំ២០២២*

# សេចក្ដីណែនាំ

## ពីការចុះឈ្មោះ ចុះវត្តមាន និងការតែងតាំងអាណត្តិគាហក: (អ្នកតំណាង) ដើម្បីចូលរួមមហាសន្និបាតភាគហ៊ុនិក លើកទី៨ របស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី

ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី ("ក្រុមហ៊ុន" ឬ "ហ្គ្រេន ធ្វីន" ឬ "ហ.ធ.អ") ជាក្រុមហ៊ុនឯកជនដំបូងបង្អស់ដែលចុះបញ្ជីលក់មូលបត្រនៅផ្សារមូលបត្រកម្ពុជា ("ផ.ម.ក") មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន និងសាធារណៈជនទាំងអស់ មេត្តាជ្រាបថា ៖ ក្រុមហ៊ុននឹងចាប់ផ្ដើមទទួលការចុះឈ្មោះចូលរួមមហាសន្និបាតភាគហ៊ុនិក លើកទី៨ របស់ក្រុមហ៊ុន ចាប់ពីថ្ងៃទី១៣ ដល់ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២ នេះតទៅ។ ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោត ដែលមានរាយនាមក្នុងបញ្ជីភាគហ៊ុនិកផ្លូវការរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន នៅថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២២ មានសិទ្ធចូលរួមមហាសន្និបាតភាគហ៊ុនិក លើកទី៨ របស់ក្រុមហ៊ុន ដែលនឹងប្រព្រឹត្តិទៅនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ បានលុះត្រាតែ ៖

### ក- ការចុះឈ្មោះចូលរួម

ភាគហ៊ុនិកអាចចុះឈ្មោះចូលរួមមហាសន្និបាតភាគហ៊ុនិក លើកទី៨ ជាមួយធនាគារ អេស៊ីលីដា ភីអិលស៊ី ដែលជាភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងទូទាត់ជំនួសរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន ដែលមានទីតាំងនៅអាគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ រៀងរាល់ថ្ងៃធ្វើការ ចាប់ពីថ្ងៃទី១៣ ដល់ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២ ចាប់ពីម៉ោង ០៨: ០០ នាទី ព្រឹក ដល់ ម៉ោង ០៤:០០ នាទី រសៀល។

ភាគហ៊ុនិកអាចចុះឈ្មោះចូលរួមមហាសន្និបាតភាគហ៊ុនិក លើកទី៨ ជាមួយ ធនាគារ អេស៊ីលីដា ភីអិលស៊ី ដែលជាភ្នាក់ងារផ្ទេរមូលបត្រ និងទូទាត់ជំនួសរបស់ក្រុមហ៊ុនបាន តាមរយៈអ៊ីម៉ែល ឬមធ្យោបាយណាមួយក៏បាន។ ភាគហ៊ុនិក អាចមកធនាគារ អេស៊ីលីដា ភីអិលស៊ី តាមអាសយដ្ឋានខាងលើ ដោយផ្ទាល់ ឬចាត់តាំងអាណត្តិគាហក: (អ្នកតំណាង) ដើម្បីទទួលបានលិខិតអញ្ជើញចូលរួមមហាសន្និបាត លើកទី៨ នេះ។

ក្នុងករណី ភាគហ៊ុនិកបានចុះឈ្មោះចូលរួមមហាសន្និបាតភាគហ៊ុនិក លើកទី៨ តែពុំបានអញ្ជើញមកទទួលបានលិខិតអញ្ជើញចូលរួមមហាសន្និបាតភាគហ៊ុនិក លើកទី៨ នេះ ភាគហ៊ុនិក នៅតែមានសិទ្ធិចូលរួមមហាសន្និបាតភាគហ៊ុនិក លើកទី៨ នេះបាន។

ភាគហ៊ុនិក ត្រូវបាត់បង់សិទ្ធិក្នុងការចូលរួមមហាសន្និបាតភាគហ៊ុនិក លើកទី៨ ប្រសិនបើ ភាគហ៊ុនិក ឬអាណាព្យាបាល: មិនបានចុះឈ្មោះតាមពេលកំណត់ខាងលើ និងមិនបានគោរពតាមសេចក្តីណែនាំនេះ។

ក្នុងពេលចុះឈ្មោះចូលរួម ភាគហ៊ុនិក ឬអាណាព្យាបាល: (អ្នកតំណាង) ទទួលបាននូវលិខិតអញ្ជើញចូលរួមមហាសន្និបាតភាគហ៊ុនិក លើកទី៨ របស់ក្រុមហ៊ុន ប្រេ្គន ធ្វីន។

***<u>សម្គាល់</u>៖ លិខិតអញ្ជើញចូលរួមមហាសន្និបាតភាគហ៊ុនិក មិនមាន ចែកជូនទៀតទេ។***

**ខ- ការចុះវត្តមាន**

មហាសន្និបាតភាគហ៊ុនិក លើកទី៨ របស់ក្រុមហ៊ុន នឹងប្រារព្ធនៅទីស្នាក់ការក្រុមហ៊ុន (តាមប្រព័ន្ធអនឡាញ) លើកលែងតែ មានការចាំបាច់ណាមួយពីការផ្លាស់ប្តូរទីតាំងប្រារព្ធមហាសន្និបាតភាគហ៊ុនិក ក្រុមហ៊ុននឹងជូនដំណឹងជូនភាគហ៊ុនិកជាមុន។

- កាលបរិច្ឆេទមហាសន្និបាតភាគហ៊ុនិក លើកទី៨ ៖ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២
- វេលាម៉ោង ៖ ចាប់ពីម៉ោង ០៨: ០០ ព្រឹក ដល់ម៉ោង ១១: ៣០ ថ្ងៃត្រង់
- ការចុះវត្តមាន ៖ ចាប់ពីម៉ោង ០៨: ០០ ព្រឹក ដល់ម៉ោង ០៩: ០០ ព្រឹក

ការខកខានពុំបានចុះវត្តមានតាមការកំណត់ខាងលើ នឹងបាត់បង់សិទ្ធិក្នុងការចូលរួមមហាសន្និបាតភាគហ៊ុនិក លើកទី៨ នេះ។

ភាគហ៊ុនិកដែលចូលរួមក្នុងមហាសន្និបាតនេះ ត្រូវយកមកជាមួយនូវលិខិតអញ្ជើញចូលរួមមហាសន្និបាត លើកទី៨ (ប្រសិនមាន) ដែលទទួលបានក្នុងពេលចុះឈ្មោះចូលរួម កាលពីថ្ងៃទី១៣ ដល់ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២ នៅធនាគារអេស៊ីលីដា ទីអិលស៊ី និងអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន។ ករណី ភាគហ៊ុនិកប្រគល់សិទ្ធិឲ្យអ្នកតំណាងមកចូលរួមជំនួស ត្រូវភ្ជាប់ជាមួយនូវលិខិតផ្ទេរសិទ្ធិ ដែលមានហត្ថលេខារបស់ភាគហ៊ុនិក និងអាណាព្យាបាល: (អ្នកតំណាង) "***លិខិតតែងតាំងអាណាព្យាបាល: (អ្នកតំណាង)***" ទៅតាមទម្រង់ដែលកំណត់ដោយក្រុមហ៊ុន ប្រេ្គន ធ្វីន។ អាណាព្យាបាល: (អ្នកតំណាង) ត្រូវយកមកជាមួយផងដែរនូវអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់ខ្លួន។

**គ- ការតែងតាំងអាណាព្យាបាល:(អ្នកតំណាង)**

ក្នុងករណី ភាគហ៊ុនិកចាត់អ្នកតំណាងមកចុះឈ្មោះចូលរួមជំនួសក្នុងមហាសន្និបាតភាគហ៊ុនិក លើកទី៨ របស់ក្រុមហ៊ុន ភាគហ៊ុនិក ត្រូវតែងតាំងអាណាព្យាបាល: (អ្នកតំណាង)។ អាណាព្យាបាល: (អ្នកតំណាង) ត្រូវដាក់លិខិតតែងអាណាព្យាបាល: (អ្នកតំណាង) ដោយភាគហ៊ុនិក ជូនក្រុមហ៊ុន នៅពេលចុះវត្តមាននៅកន្លែងប្រារព្ធពិធី ដើម្បីចូលរួមមហាសន្និបាតភាគហ៊ុនិក លើកទី៨ នេះ ។

ក្នុងករណីភាគហ៊ុនិកចាត់អ្នកតំណាងមកចូលរួមជំនួសក្នុងមហាសន្និបាតភាគហ៊ុនិក លើកទី៨ របស់ក្រុមហ៊ុន ភាគហ៊ុនិកត្រូវតែងតាំង អាណាព្យាបាល: (អ្នកតំណាង) ទៅតាមទម្រង់ "***លិខិតតែងតាំង អាណាព្យាបាល: (អ្នកតំណាង)***" ដែលកំណត់ដោយក្រុមហ៊ុន។

ភាគហ៊ុនិកម្នាក់អាចតែងតាំងអាណាព្យាបាល: (អ្នកតំណាង) តែម្នាក់ប៉ុណ្ណោះ។ ភាគហ៊ុនិកច្រើននាក់ អាចតែងតាំង អាណាព្យាបាល: (អ្នកតំណាង) រួមគ្នាបាន។

ទម្រង់ "***លិខិតតែងតាំង អាណាព្យាបាល: (អ្នកតំណាង)***" មាន ពីរប្រភេទ គឺ សម្រាប់ភាគហ៊ុនិកជា នីតិបុគ្គល និង ភាគហ៊ុនិកជា រូបវន្តបុគ្គល។

ដើម្បីផ្តល់ភាពងាយស្រួលដល់ភាគហ៊ុនិក ទម្រង់លិខិតតែងតាំងអាណាព្យាបាល: (អ្នកតំណាង) ត្រូវបានរៀបរៀងជា ពីរ ភាសា គឺ ភាសាខ្មែរ និងភាសាអង់គ្លេស។ ភាគហ៊ុនិក អាចជ្រើសរើសទម្រង់លិខិតជាភាសាណាមួយក៏បាន។

សម្រាប់ព័ត៌មានលម្អិតពីការចុះឈ្មោះចូលរួមមហាសន្និបាតភាគហ៊ុនិក លើកទី៨ ភាគហ៊ុនិក អាចទាក់ទងមក លោកស្រី **ឃឹម រស្មី** តាមរយ:ទូរស័ព្ទលេខ (៨៥៥)១២ ២២២ ៥០៥ ឬ តាមអ៊ីម៉ែល qmig.ac08@qmico.com ឬតាមរយ:ធនាគារ អេស៊ីលីដា ភីអិលស៊ី ជាភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងទូទាត់ជំនួសរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន ដូចខាងក្រោម ៖

- អាសយដ្ឋាន: អាគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
- ទូរស័ព្ទ: (៨៥៥)២៣-៩៩៨ ៧៧៧ (ភ្ជាប់ទៅ: ៨៣១៦៧)
- ទូរសារ: (៨៥៥)១៥ ៦០០ ៧៤៣
- ទូរស័ព្ទដៃ: (៨៥៥)១៥-៦០០ ៧៤៣
- អ៊ីម៉ែល: lim.an@acledabank.com.kh

**ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ីនធើណាសិនណល (ខេមបូឌា) ភីអិលស៊ី**